# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សីលធម៌សម័យសង្គមរាស្ត្រនិយមល្អជាងសីលធម៌បច្ចុប្បន្ននេះ ។

www.hoksavann,com

ថ្ងៃទី២៣ កញ្ញា ២០១០



សូមប្រៀបធៀបចំពោះតែសីលធម៌និងផ្នែកសង្គមកិច្ចខ្លះក្នុងសម័យសង្គមរាស្ត្រនិយមមករបបប្រជាធិបតេយ្យសេរីពហុបក្សសម័យបច្ចុប្បន្ននេះ ពុំប្រៀបធៀបបញ្ហានយោបាយឡើយ ។ សម័យសង្គមរាស្ត្រនិយម ដែលដឹកនាំដោយព្រះករុណាសម្តេចនរោត្តម-សីហនុ អតីតព្រះមហាក្សត្រខ្មែរ ប្រជាពលរដ្ឋខ្មែរនៃព្រះរាជាណាចក្រកម្ពុជាមានសីលធម៌ល្អណាស់ ប្រទេសមានសន្តិភាព ជីវភាពរបស់ប្រជាពលរដ្ឋខ្មែរមានភាពធូរធា ដែលយើងសូមលើកយកភស្តុតាងខ្លះមកពណ៌នាដូចតទៅនេះ ៖

រាជរដ្ឋាភិបាលខ្មែរសម័យនោះ បានកំចាត់ការលេងល្បែងស៊ីសងយ៉ាងម៉ឹងម៉ាត់បំផុត ជាលទ្ធផលសម័យនោះពុំសូវមានអ្នកលេងល្បែងស៊ីសងឡើយ ក្រោយមកទើបមានបង្កើតល្បែងកាស៊ីណូ ដើម្បីប៉ះប៉ូវថវិកាជាតិ ។ ចោរលួចចោរប្លន់ក៏ពុំសូវកើតមាន ។ ស្រូវរបស់កសិករខ្មែរបានទុកចោលក្នុងលានវាលស្រែគ្មានយាមសោះ ប៉ុន្តែពុំមានចោរលួចឡើយ ។ យុវនារីទោះបីដើរតែម្នាក់ឯង ឬដើរជាមួយបុរស ក៏យុវនារីនោះពុំមានការរំលោភពីបុរសឡើយ ។ មាតាបិតាតែងរក្សាកិត្តិយសគ្រួសារ ជាពិសេសកិត្តិយសកូនស្រី មិនដែលលក់កូនស្រីរបស់ខ្លួនឲ្យទៅជនដទៃឡើយ ទោះបីក្រីក្រលំបាកយ៉ាងណាក៏ដោយ ។ ប្រជាពលរដ្ឋខ្មែរពុំពេញចិត្តធ្វើចំណាកស្រុកទៅធ្វើការនៅបរទេសឡើយ ។ អំពើហឹង្សាពុំសូវកើតមាន ។ ជីវភាពរបស់ប្រជាពលរដ្ឋបានធូរធា ឪពុកម្នាក់អាចរកស៊ីចិញ្ចឹមកូន៨-១០នាក់បាន ហើយមានពេលទំនេរអាចដើរកំសាន្តថែមទៀត ដោយគ្មានឮថាមានខ្មែរខ្លះស្លាប់ព្រោះអត់បាយឡើយ ។ ប្រាក់បៀវត្សរ៍គ្រូបង្រៀននិងអ្នករាជការមានកំរិតខ្ពស់ ។ ការព្យាបាលរោគពុំយកប្រាក់ពីប្រជាពលរដ្ឋឡើយ។មានសារពត៌មានឯកជន ប៉ុន្តែពុំឮថា ចាប់អ្នកសារពត៌មានឲ្យបង់ផាកពិន័យ ឬដាក់ពន្ធនាគារឡើយ។ព្រៃឈើនៅប្រទេសកម្ពុជាទាំងមូលនៅគង់វង់ គ្មានការលួចកាប់ពីជនទុច្ចរិតឡើយ ។ ដីស្រែចំការរបស់ប្រជាពលរដ្ឋ គ្មានការរំលោភពីអ្នកមានអំណាចឡើយ ។ ឯស្ថាប័នរបស់ព្រះសង្ឃ ក៏ស្ថិតនៅឯករាជ្យ ។ល។

សម័យរបបប្រជាធិបតេយ្យសេរីពហុបក្ស ហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវ ស្ពាន ទំនប់ទឹក សាលារៀន មន្ទីរពេទ្យ រថយន្តគ្រប់ប្រភេទ កង់ ម៉ូតូ រហូតវត្តអារាមពុទ្ធិកសិក្សា មានការចំរើនលូតលាស់ជាងសម័យសង្គមរាស្ត្រនិយម ប៉ុន្តែសីលធម៌មានលក្ខណៈទន់ខ្សោយ ។

ស្រីពេស្យាបានកើនឡើងគ្រប់ទិសទីនៃប្រទេសកម្ពុជា ជាហេតុនាំឲ្យកើតរោគអេដស៍ក៏មានចំនួនច្រើន ។ មានការរំលោភស្ត្រីភេទ រហូតឪពុកមា ឪពុកចុង រំលោភលើក្មួយលើកូនដើមរបស់ខ្លួនថែមទៀត ។ អំពើគួរឲ្យរន្ធត់មួយទៀត មានម្តាយខ្លះបានចាញ់បោកការបញ្ឆោតរបស់មេអណ្តើក ប្រគល់កូនស្រីខ្លួនទៅឲ្យគេ ដើម្បីបានប្រាក់កាសខ្លះមកដោះស្រាយជីវភាពក្រីក្ររបស់ខ្លួន ដែលកូនស្រីរបស់ខ្លួនត្រូវគេយកទៅធ្វើជាស្រីកំណាន់ចិត្ត ឬជាស្រីពេស្យា ។ ប្រជាពលរដ្ឋខ្មែរជាច្រើនបានធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស ។ ស្ត្រីខ្មែរអភ័ព្វខ្លះបានត្រូវគេរំលោភ ដូចជាស្ត្រីខ្មែរទៅធ្វើការបំរើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ដែលកាន់សាសនាឥស្លាមជាដើម ។ មានអំពើហឹង្សាកើតមានជាច្រើន ដូចជាអំពើហឹង្សាក្នុងគ្រួសារ អំពើហឹង្សាកើតអំពីការចងគំនុំគ្នា រហូតដល់អំពើហឹង្សាក្នុងផ្លូវនយោបាយ ។ មានចោរលួចចោរប្លន់ ក៏កើតមានជាច្រើនកន្លែង ។ ជីវភាពរបស់ប្រជាពលរដ្ឋភាគច្រើននៅមានភាពទន់ខ្សោយ ។ ឯបៀវត្សរ៍របស់គ្រូបង្រៀន និងរបស់អ្នករាជការទូទៅមានកម្រិតទាបណាស់ ពុំអាចរស់នៅជាសមរម្យបានឡើយ ។ មានការចាប់គណបក្សប្រឆាំងនិងអ្នកសារពត៌មានខ្លះ ដែលរិះគន់រាជរដ្ឋាភិបាលដាក់ពន្ធនាគារ ។ ព្រៃឈើប្រទេសកម្ពុជាបានកាប់បំផ្លាញ ។ ដីធ្លីរបស់ប្រជាពលរដ្ឋ បានត្រូវអ្នកមានអំណាចរំលោភយកទៅលក់ឲ្យក្រុមហ៊ុន ។ ស្ថាប័នរបស់ព្រះសង្ឃពុំឯករាជ្យ ។ល។

អ្នកដឹកនាំខ្មែរសម័យបច្ចុប្បន្ននេះ គប្បីបំពេញកន្លែងដែលខ្វះខាតនិងកន្លែងដែលប្រព្រឹត្តឆ្គង ដើម្បីឲ្យប្រទេសកម្ពុជាប្រព្រឹត្តទៅជាប្រទេសនីតិរដ្ឋ ។ មួយទៀត ត្រូវរៀបចំកម្មវិធីអប់រំសីលធម៌ក្នុងក្រសួងអប់រំ ឲ្យសិស្សនិងនិស្សិតសិក្សាគ្រប់ភូមិសិក្សាឲ្យបានខ្លាំងក្លាថែមទៀត ដើម្បីឲ្យសីលធម៌មានកម្រឹតខ្ពស់ឡើង ។ ក្នុងសម័យសាកលភាវូបនីយកម្មនេះ វិទ្យុ ទូរទស្សន៍ សារពត៌មាន ទស្សនាវដ្តី កុំផ្សាយរឿងអាសអាភាសនិងរឿងទាក់ទងនឹងអំពើហឹង្សា ដែលជាគំរូពុំល្អសំរាប់សិស្សនិងនិស្សិតខ្មែរ ។ ការសិក្សាអប់រំ គួរដកស្រង់យកព្រះធម៌របស់ព្រះពុទ្ធ ឲ្យសិស្សនិងនិស្សិតសិក្សារៀនសូត្រ ព្រោះព្រះធម៌របស់ព្រះពុទ្ធមានកម្រឹតសីលធម៌សាកល ដែលគ្រប់វប្បធម៌ផ្សេងគ្នាអាចទទួលយកបាន ដូចពាក្យព្រះពុទ្ធថា សេចក្តីសុខសន្តិភាពកើតមានព្រោះការមិនបៀតបៀនគ្នា ។ មួយទៀត ដោយប្រទេសកម្ពុជាដែលប្រជាពលរដ្ឋខ្មែរច្រើនលើសលប់គោរពព្រះពុទ្ធសាសនា រហូតធម្មនុញ្ញដាក់ថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋផង ដូច្នេះការលើកយកព្រះពុទ្ធសាសនាមកសិក្សា គឺស្របតាមទំនៀមទំលាប់ខ្មែរផង ស្របតាមច្បាប់កំពូលរបស់ប្រទេសផង ។៚

❑